# ការសំភាស៏របស់បងស្រី កួច សុខា

កៈ អ្នកដែលសំភាស៏គេនិង សួន សុខលី ខៈ អ្នកដែលត្រូវបានគេសំភាស៏ កួច សុខា

កៈ ជំរាបសួរបងជាដំបងខ្ញុំសូមថ្លែងអំណារគុណដល់បងដែលអោយខ្ញុំ ធ្វើការសំភាស៏ជីវប្រវិត្តរបស់បងស្រី។ ហើយការសំភាស៏នេះគឺធ្វើឡើងដោយសារ សកលវិទ្យាល័យ BYU ដោយសារតែសកលវិទ្យាល័យនិងចង់ថៃរក្សាជីវប្រវិត្តជីដូនជីតារបស់បង ហើយទុក្ខអោយកូនចៅជំនាន់ក្រោយរបស់បងស្រីមើលបន្ទាប់ពីការសំភាស៏នេះរួចហើយ តើខ្ញុំអាចសុំដាក់ការសំភាស៏មួយនិងនៅក្នុងប្រព័ន្ធវិបផ្សាយមួយដែលមានឈ្មោះថា WWW. Cambodianoralhistories.byu.edu បានដែលឬទេបង?

ខៈ ចា។

កៈ ហើយអើជាដំបង ខ្ញុំអ្នកសំភាស៏មានឈ្មោះថា សួន សុខលី។ ហើយចឹងការសំភាស៏នេះធ្វើឡើងនៅថ្ងៃទីអើ ២០ ខែ ០១ ឆ្នាំ ២០១៨ ហើយធ្វើនៅភូមិ ០៤ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

កៈ ចឹងខ្ញុំចង់សួរថា តើនាមត្រកូនរបស់បងមានឈ្មោះអីគេដែលបង?

ខៈ ចាខ្ញុំឈ្មោះ កួច សុខា។

កៈ ចាបងមានឈ្មោះកួច សុខា ហើយបងស្រីមានឈ្មោះនិងដូចជាអត្តសញ្ញាណនប័ណ្ណដែលមែនទេបង?

ខៈ ចារដូច។

កៈ ចា។ហើយចឹងចង់សួរថា បងមានឈ្មោះហៅក្រៅទេបង?

ខៈ ហៅក្រៅនៅនិងគេហៅ អាមុំ។

កៈ អាមុំ។ ចាអរគុណបង ចឹងខ្ញុំចង់សួរទៀតថា តើបងមានអាយុប៉ុន្មានដែលឥឡូវនិង?

ខៈ ចាខ្ញុំអាយុ សាមសិបប្រាំឆ្នាំ។

កៈ អាយុ សាមសិបប្រាំហើយ។ ហើយអើបងកើតនៅឆ្នាំណា ថ្ងៃណា ខែណា ដែលបង?

ខ៖ ខ្ញុំកើតនៅឆ្នាំ មួយពាន់ប្រាំបួនរយ ប៉ែតសិបបី កើតថ្ងៃទី ដប់ពីរ ខែប្រាំមួយ។

ក៖ ចារហើយចុះទីកន្លែងកំណើតវិញបងនៅណាដែល?

ខ៖ កើតនៅភ្នំពេញយើងនិង។

ក៖ ចាភ្នំពេញយើងនិង ភូមិអី ឃុំអីដែលបង?

ខ៖ គឺនៅភូមិបួននិង សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន។

ក៖ ចាអរគុណបង ចឹងបងកើតនៅផ្សារដើមថ្កូវ ភូមិបួន សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន។

ខ៖ ចា។

ក៖ ហើយចឹងចង់សួរបងថា តើបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែល?

ខ៖ ខ្ញុំមានបងប្អូនប្រាំពីរនាក់។

ក៖ ចា។ ចឹងតើអើបងអាចរៀបរាប់ឈ្មោះ កូនទីមួយនៅក្នុងក្រុមគ្រួសារបងរហូតគ្រប់ទាំងប្រាំពីរនាក់និងបានទេបង?

ខ៖ ចារបងទីមួយឈ្មោះ កួច ចាន់ថា បងទីពីរឈ្មោះ កួច ចាន់ថាល់ បងទីបីឈ្មោះ កួច គឹមសៀង បងទីបួនឈ្មោះ កួច ចាន់ធន់ មួយទៀតឈ្មោះ កួច ចាន់ធូន មួយទៀតគឺរូបខ្ញុំហើយនិងប្អូនស្រីខ្ញុំឈ្មោះ កួច សុខា និង កួច សុខុំ។

ក៖ ចាចឹងអរគុណច្រើនបង។ ហើយអើជាកិច្ចបន្តទៀត ខ្ញុំចង់សួរបងថាតើឥឡូវនិងពួកគាត់រស់នៅណាដែលបង?

ខ៖ បែកគ្នានៅ មើលមួយទៀតនៅឈ្មោះ កួច ចាន់ថុលនិងគាត់បាត់ខ្លួនហើយ។

ក៖ ចា។

ខ៖ ខ្ញុំអត់ដឹងថាគាត់ងាប់ឬក៏រស់ទេ។ ហើយក្រៅពីនិងគឺនៅភ្នំពេញនិងទាំងអស់គ្នា នៅបឹងត្របែក បើបងទីបួននិងគាត់នៅឆ្ងាយ នៅប្រហែលជានៅអើស្ទឹគេ រំវង់មូលចោមចៅនុះ ផ្លូវជាតិលេខបីរ ក្រៅពីនិងគឺនៅនិងជុំគ្នាទាំងអស់។

កៈ ចាអរគុណច្រើនបង។ ចឹងអាចរៀបរាប់ពីប្រវិត្តរបស់បងតិច
កាលពីបងនៅក្មេងជាមួយនិងបងប្អូនរបស់បង បងធ្លាប់ធ្វើអីខ្លះ?
ដូចជាលេងបីឡុកបីឡរជាមួយគ្នាឬក៏អីចឹងណាបង?

ខៈ នៅពីក្មេងគឺពួកខ្ញុំដើររើសអែតចាយមួយគ្នា។

កៈ ចារ។

ខៈ រើសអែតចាយហើយ ពេលព្រឹកក្រោបម៉ោងពីរ ម៉ោងបីរដើរបេះបន្លែត្រកួនអីនិង
ផ្ការអង្ការដីដើម្បីអោយបងខ្ញុំនិងយកទៅលក់ នៅច្បារអំពៅ។ ហើយ
បងខ្ញុំស្រីនិងគាត់កាច់ផ្ការ កាច់អើកំប្លោកនិងឈូតយកទៅយកខ្សែវានិងលក់។
ហើយក្រោយមកដល់ភ្លើរពួកខ្ញុំនាំគ្នាទៅរើសអែតចាយ។

កៈ ចា។

ខៈ ទៅរើសអែតចាយរៀនពេលព្រឹក ទៅរើសអែតចាយពេលល្ងាច រើសល្ងាចរៀនព្រឹក។

កៈ ចា។

ខៈ ហើយបានជួបនិងអំឈៀវ
គាត់ធ្វើការនៅសាលាជ័យជំនះនិងគាត់អោយខ្ញុំនិងបានចូលរៀន។
គាត់ឃើយខ្ញុំក្មេងរើសអែតចាយ ហើយគាត់សួរខ្ញុំថាខ្ញុំនិងមានម៉ែឪអត់?
ខ្ញុំថាខ្ញុំមានអត់មានតែម្ដាយទេខ្ញុំមានតែឪពុក ហើយគាត់សួរខ្ញុំថាខ្ញុំចង់រៀនអត់? ខ្ញុំថាខ្ញុំចង់
អញ្ចឹងគាត់អោយខ្ញុំថាបើមករៀនគាត់អោយខ្ញុំមួយថ្ងៃប្រាំរយគាត់ថាចឹង។
កាលនិងមួយថ្ងៃប្រាំរយនិងវាច្រើនដែល។
ខ្ញុំពីនាក់បងប្អូននិងដើររើសអែតចាយពីនាក់ប្អូនខ្ញុំមីស្រីនិង
គាត់ឃើញចឹងគាត់ក៏ប្រាប់ខ្ញុំថានៅជិតផ្ទះនិងមានស្គាល់ក្មេងពីណាខ្លះដែលអត់បានរៀន
អោយហៅមកៗដល់ហើយគាត់ហៅអោយទៅ គាត់អោយមួយថ្ងៃប្រាំរយ
គាត់បើកសៀវភៅ ការតាប
ស្បែកជើងថ្មីៗអីនិងអោយពួកខ្ញុំទាំងអស់ហើយខ្ញុំឆ្លៀតរើសអែតចាយបណ្ដើរ
ឆ្លៀតទៅរៀនបណ្ដើរ។ ហើយធ្វើម៉េចអោយតែបានលុយចូលផ្ទះដើម្បីផ្គត់ផ្គង់ជីវភាព
ពួកខ្ញុំនៅជាមួយនិងបងស្រីកាលនិង រហូតដស់ពេលខ្ញុំមានប្ដីមានគ្រួសារ។
ខ្ញុំមានម៉ែឪចិញ្ចឹមធម៍។

កៈ ចារ។

ខៈ អាឡូវប៉ាធម៌ចិញ្ចឹមគាត់នៅតែជួយចិញ្ចឹមខ្ញុំនិង តែតិចទូចអីនិងគាត់ចេះតែជួយហូចមក គាត់ផ្តល់អោយ។

កៈ ចា។

ខៈ រហូតដល់ខ្ញុំមានគ្រួសារមុននិង តែឥឡូវខ្ញុំបែកគ្នា។ ខ្ញុំជួបទើបតែជួបគ្រួសារខ្ញុំថ្មីនិង។

កៈ ចា។

ខៈ ប្តីខ្ញុំគាត់នៅខាងល្វាអែម។

កៈ ចាចឹងអរគុណច្រើនបងស្រីសំរាប់ការរៀបរាប់ពីប្រវិត្តរបស់បង។ ហើយចឹងខ្ញុំចង់សួរបងទៀតថាតើអើម្តាយរបស់បងមានឈ្មោះអ្វីដែលបង?

ខៈ ម៉ែខ្ញុំមានឈ្មោះថា ទឹង ថាច។

កៈ ចាចុះឪពុកបង?

ខៈ ប៉ាខ្ញុំឈ្មោះ កួច ចឹង។

កៈ ចាចុះពួកគាត់ឥឡូវមានអាយុប៉ុន្មានហើយបង?

ខៈ ខ្ញុំ ខ្ញុំដឹងតែប៉ាខ្ញុំកើតឆ្នាំថោះ ម៉ាក់ខ្ញុំឆ្នាំខ្លា។

កៈ ចាប្រហែលជា។

ខៈ ចិតជាងហើយ។

កៈ អរចិតជាងហើយ។

ខៈ ចារឪពុកខ្ញុំរាល់ថ្ងៃនៅនិងដែលនិង។

កៈ ចាចុះគាត់នៅរស់នៅឡើយតាស់អីបង?

ខៈ ចា។

កៈ ពួកគាត់នៅរស់ទាំងពីរ?

ខ៖ ឪពុកខ្ញុំនៅ តែម្ដាយខ្ញុំស្លាប់បាត់ហើយ។ ស្លាប់តាំងតែពីខ្ញុំនៅអាយុប៉ុន្មាន
ខ្ញុំបានបួនប្រាំឆ្នាំនុះ។

ក៖ ចា។

ខ៖ ខ្ញុំមិនទាំងចាំនាំមុខគ្នាត់ផងនិង។

ក៖ ចាចុះបងចាំថាម្ដាយរបស់បងគាត់ស្លាប់និងនៅឆ្នាំណាដែល ពេលណាទេបង?

ខ៖ កាលនិងខ្ញុំអត់បានដឹងថាឆ្នាំណាទេ
តែខ្ញុំដឹងថាកាលនិងខ្ញុំអាយុទើបតែបានបួនប្រាំឆ្នាំ។

ក៖ ចា។

ខ៖ គាត់ឈឺរូកគាត់ច្រើនណាស់។

ក៖ ចា។

ខ៖ គាត់ស្លាប់នៅក្រាំងញឹយងនុះ ស្រុករបស់គាត់។

ក៖ ចាចុះអាឡូវបងអាយុប៉ុនន្មានហើយបង?

ខ៖ ខ្ញុំមានអាយុសាមសិបប្រាំហើយ។

ក៖ ចាចឹងបងអាយុសាមសិបប្រាំ ហើយម៉ាក់របស់បងស្លាប់ថាបងអាយុប្រាំឆ្នាំចុះចឹង។

ខ៖ ចា។

ក៖ ចឹងគិតថាសាមសិបឆ្នាំមុនម៉ែនទេបង?

ខ៖ ចាកាលសាមសិបឆ្នាំមុននិងហើយ។

ក៖ ចាហើយចឹងខ្ញុំចង់សួរបងថាតើបងដឹងថាឪពុកម្ដាយរបស់បងគាត់កើតនៅឆ្នាំណា
ខែណាអត់បង?

ខ៖ ចាដឹង។ អើឪពុកខ្ញុំកើតនៅឆ្នាំមួយពាន់ប្រាំបួនរយសែសិបមួយ អរសែសិបពីរ
ម៉ែខ្ញុំកើតនៅឆ្នាំមួយពាន់ប្រាំបួនរយសែសិបមួយ។

ក៖ ចាហើយចុះពួកគាត់មានស្រុកកំណើតនៅណាដែលបង?

ខ៖ ប៉ាខ្ញុំគាត់នៅខាងកំពង់ចាំនៅឯវត្តអំពិល ព្រៃកដំបូក។

ក៖ ចា។

ខ៖ ហើយបើម៉ែខ្ញុំនៅខេត្តក្រាំងញឹង ស្រអាងព្រៃកតូចយើងនេះ។

ក៖ ចា។

ខ៖ ស្រុកកំពង់ហើយវត្តអណ្តូងនិង។

ក៖
ចាហើយអើខ្ញុំចង់សួរបងថាតើឪពុករបស់បងណាគាត់បានធ្វើអីសំរាប់ចិញ្ចឹងជីវិតរស់គាត់ណាបង? ហើយនិងកូនៗណា?

ខ៖ គាត់រាស់ថ្ងៃគាត់នៅជាមួយចៃខ្ញុំនិង
គាត់ចាស់ហើយគាត់ធ្វើអីអត់កើតទេគាត់មានជំងឺទឹកនោមផ្អែមផងអីផង
ហើយគាត់នៅតែផ្ទះ បងខ្ញុំនិងលក់លៀសចិញ្ចឹមគាត់និង។

ក៖ ចាអើចង់និយាយថាពីមុនមកណាបង? ដូចជាពេលគាត់នៅក្មេងណាហើយពេលមាន?

ខ៖ ប៉ាខ្ញុំគាត់ប៉ះកង់។

ក៖ ចា។

ខ៖ តែគាត់អើ គាត់ម្លាប់ប្រាប់ខ្ញុំថាគាត់និងធ្លាប់អ្វើជាគ្រូបង្រៀន។

ក៖ ចា។

ខ៖ តែប៉ុននិងហើយ។

ក៖ ចាហើយចុះម្តាយរបស់បងវិញបង?

ខ៖ ម៉ែខ្ញុំនុះ ម៉ែគាត់អើ កាលគាត់នៅរស់គាត់ដើររកស៊ីអីគេដូរស្រូវ
បុកស្រូវយកការទក់ម៉េចទេ គាត់និងខ្ញុំអត់ដឹងដែល ខ្ញុំមិនសូវចាំទេនៅតូចៗ។

ក៖ ចាបងចា។ ហើយចឹងអើខ្ញុំចង់សួរបងថា
តើបងនៅចាំសាច់រឿងអីខ្លះអំពីឪពុកម្តាយរបស់បងណាដូចជាពេលដែលបងនៅក្មេងតើបងបានលេងអីខ្លះជាមួយគាត់? ហើយគាត់ម៉េចដែលជាមួយកូនៗអីចឹងណា?

ខ៖ ប៉ាម៉ាក់ខ្ញុំមិនដែលវៃខ្ញុំទេ ប៉ាក៏អត់ដែលវៃដែលតែខ្ញុំចាំបានថា ថាប៉ាខ្ញុំគាត់ធ្លាប់ប្រកែកគ្នាជាមួយម៉ាក់ខ្ញុំរឿងកោសខ្យល់ កោសខ្យល់អោយខ្ញុំហើយនិងប្អូនស្រីខ្ញុំនិងណា។

ក៖ ហាហាហា ចាបង។

ខ៖ ប៉ាខ្ញុំ ម៉ែខ្ញុំ ប៉ាគាត់ទារកោសម្លូរ ដល់ពេលម៉ែគាត់ថាអត់ទេ គាត់ទារកោសសេន ហើយទៅខ្ញុំលឺគាត់ប្រកែកគ្នា រួចទៅគាត់ថាពួកវាធំហើយគ្រាន់តែកោសសេនទៅចាំបាច់អីអោយប្រើម្លូរកោសមើលតែកូនក្មេងមួយខូបម៉េច។

ក៖ ចាបង។

ខ៖ ម៉ែឪខ្ញុំគាត់ប្រកែកគ្នាតែប៉ុននិងគាត់អត់ដែលចេះឈ្លោះគ្នាទេ។ ហើយបើខ្ញុំនៅតូចៗខ្ញុំកើតបោសជើង។

ក៖ ចាបង។

ខ៖ បោសសជើងទៅខ្ញុំដើរវៀងពៀកៗជើងនិងណា ប្អូនស្រីខ្ញុំមីផ្លោះមួយខ្ញុំនិងវា ខ្ញុំដើរអូសជើងខ្ញុំរហូតដល់ប្អូនខ្ញុំនិងវាដឹងរត់មកពីណាទេ ស្រាបតែវារត់មកបុកជើងខ្ញុំផ៉ាង ក៏ជើងខ្ញុំវៀកមួយជំហៀងនិងក៏ខ្ញុំដើរមកត្រង់ជើងវិញ រួចទៅថាខ្ញុំយំអើយយំ ប៉ាខ្ញុំគាត់លួងខ្ញុំ លួងខ្ញុំហើយគាត់ប្រថៃសប្រាប់ថាកុំវាញប្អូនចឹងណា ចាំប៉ាវៃអោយចាំប៉ាវៃអោយកុំយំណា ប្អូនវាអត់ដឹងអីទេ ប្អូនអត់បានតាំងចិត្តចឹងកុំខឹងៗ ហើយប៉ាខ្ញុំគាត់ទៅចេរប្អូនខ្ញុំថា កូនមីចោតាប៉ែតតោ។

ក៖ ហាហាហា ចា។

ខ៖ គាត់អត់ដែលចេះវៃកូន អត់ដែលចេះចេកូនអីទេ ពាក្យអសុរ្សរស់គាត់អត់ដែលចេះប្រើចេកូនទេ។

ក៖ ចាអញ្ចឹងអរគុណបង។
អញ្ចឹងអើដូចជាឪពុកម្ដាយរបស់បងគាត់ធ្លាប់ប្រាប់អំពីអើជីវិតរបស់គាត់កាលនៅពីក្មេងតូចៗគាត់ធ្វើអីខ្លះអត់បង? ពួកគាត់ធ្លាប់និយាយរឿងគាត់នៅក្មេងៗប្រាប់អត់?

ខ៖ គាត់អានិងខ្ញុំ គាត់ធ្លាប់និយាយកាលខ្ញុំនៅតូចខ្ញុំអត់ចាំទេ។

ក៖ ចា។

ខ៖ ខ្ញុំអត់បានចាំទេ តែបើប៉ាខ្ញុំបានគាត់និយាយ អាឡូវគាត់ក៏នៅរស់ដែល គាត់ថាគាត់កាលនៅពីក្មេងកាលកុងនិយាយាប្រដៅគាត់ណាអ្វីក៏ដោយបើគាត់កំពង់តែនិយាយចឹង គាត់របៀបថាគាត់និយាយអោយទៅធ្វើខ្សៀលគោរ ឬក៏ទៅជីកដំឡូរអីចឹង កុំពង់តែនិយាយចឹងប៉ាខ្ញុំ អត់ងើបស្ទូសទៅយកចប ឬក៏អីចឹង អត់ក្រោមអត់អីនិងគឺគាត់វៃហើយ។

ក៖ អើចាបង។

ខ៖ តែប៉ាខ្ញុំគាត់ថាជំនាន់គាត់ណា មិនមែនដូចជំនាន់នេះទេ ជំនាន់អាឡូវនិងពីបាកនិយាយណាស់។

ក៖ ចា។

ខ៖ ក្មេងៗអាឡូវនិយាយមិនស្រួល តរម៉ាត់អោយប៉ប៉េះ។

ក៖ ចា។

ខ៖ ជំនាន់គាត់ណាគ្រាន់តែសំលឹងមើលតែមុខទេក៏ខ្លាចដែល តែជំនាន់នេះគាត់ថាពីបាកណាស់ ពីបាកប្រដៅណាស់ក្មេង។

ក៖ ចា។

ខ៖ មិនដូចកាលជំនាន់ពួកគាក់ទេស្រួលណាស់ ហើយកាលគាត់ គាត់ថាកូនៗគាក់ដូចពួកខ្ញុំអីនិង។

ក៖ ចា។

ខ៖ ជំនាន់ពួកខ្ញុំនិងក៏មិនដែលពីបាកនិយាយអីដែល។

ក៖ ចា។

ខ៖ តែមកដល់ពួកគាត់ឃើញថៅនិងគាត់មកនិយាយថារឹតតែទៅទៀតហើយ។

ក៖ ហាហាហា ចាបង។

ខ៖ តែប៉ាខ្ញុំគាត់ថាមិនដែលកូនខ្ញុំឯណាមួយនិយាយគ្នាស្តាប់មិនបានទេ។ មកចៅណាតែនិយាយមិនស្រួលស្រែក ក្មួយអីនិងតែនិយាយមិនស្រួលស្រែកឈ្លើយៗណាស់។

ក៖ ចាបង។ អញ្ចឹងអរគុណបង អញ្ចឹងខ្ញុំចង់អើបងទៀតថាតើបងអើធ្លាប់អើដឹងអំពីជីវប្រវិត្តជីដូនជីតារបស់បងណាស់ តើម្តាយខាងឪពុកអីនិង ឪពុកម្តាយគាត់មានឈ្មោះអី?

ខ៖ ខ្ញុំអត់ចាំឈ្មោះអីទេ តែដូចជាឈ្មោះកុង កុងៗកុងឡាវអី។

ក៖ ចា។

ខ៖ ខ្ញុំចាំឈ្មោះតែកុងទេ ម៉ារខ្ញុំអត់ចាំទេព្រោះខ្ញុំអត់ដែលបានឃើញមុខគាត់ទាំងអស់គ្នានិង។

ក៖ ចា ហើយចុះខាងឪពុកអីនុះបងមានចាំឈ្មោះពួកគាត់អត់?

ខ៖ បើខាងឪ។

ក៖ ឪពុកខាងម្តាយណាស់?

ខ៖ និងអានិងចាំឈ្មោះតែឪពុកនិង ខាងជីតា ខាងកុងចាំឈ្មោះកុងឡឺរ បើម៉ែនិងអត់ចាំទេ។

ក៖ ចា។

ខ៖ អត់ចាំម៉ងនិង ព្រោះអី។

ក៖ បងនៅតូចពេច?

ខ៖ ចារ។ ខ្ញុំនៅតូចម៉ងនិងណាស់ អត់ដឹងចាំអត់បានម៉ងនិង ហើយក៏អត់ដែលសួរគាត់ផងដែល។

ក៖ ហាហាហា។ ចាបង ហើយចឹងថ្ងៃខែឆ្នាំកំណើតគាត់អីក៏បងអត់ចាំដែលមែនទេ អត់ដឹងដែលមែនទេបង?

ខ៖ ចារ។ ខ្ញុំអត់ដឹងម៉ង ព្រោះអត់ដែលបានសួរទៅប៉ាហើយណាមួយប៉ាគាត់នៅមួយថៃ ខ្ញុំនៅដោយខ្ញុំខាងនេះ ថៃគាត់រវល់ដើរតាមប្តីគាត់ធ្វើការសំណង់ចឹងទៅ ជូនកាលដើរើសអែតចាយអីចឹងទៅ។

ក៖ ចា។

ខ៖ ហើយនៅផ្ទះមើលកូនទៅព្រោះអី ខ្ញុំធ្លាប់វាស់តាស កាលខ្ញុំកូនខ្ចីនិងខ្ញុំវាស់ ប្តីខ្ញុំនិងក៏វាសដែល។វាសខ្ញុំបានមួយខែកន្លះ ប្តីខ្ញុំវាសត្រូវវាសដែល។

ក៖ បងវាសអីគេដែលបង បងវាសអី?

ខ៖ ខ្ញុំវាសកូន។

ក៖ វាសកូន។

ខ៖ ខ្ញុំកូនក្រៅស្បូន។

ក៖ ចា។

ខ៖ ប្តីខ្ញុំវះសពោះរៀនដុះខ្នែង តែខ្ញុំកំសត់ណាស់កាលនិង កាលនិងបានមីងគាត់នៅនិង គាត់បានជួយនិយាយសុំអង្គរការគេអោយជួយ។ កាលពីមុននិងខ្ញុំមានអង្គរការគេជួយដែលតែឥឡូវ អង្គរការនិងគេថាខ្ញុំអស់អើ អស់អាណាត់ហើយ ព្រោះអីអង្គរការមួយឆ្នាំគេចុះមកម្តង គេចុះមកសំភាស៍ខ្ញុំអី ខ្ញុំបានអង្គរការសប្បុរសធម៌។

ក៖ ចារបានគេផ្តល់ជំនួយអោយបងតិចៗចឹងទៅបង? ឬក៏អត់ទេ?

ខ៖ អត់ទេគេអត់ផ្តល់អោយទេ គេផ្តល់អោយរបៀបថាជាសុខភាពយើងនិងណា។

ក៖ ចា។

ខ៖ ពេលដែលខ្ញុំត្រូវការទៅពេទ្យពេលឈឺនិងវះសកាត់អី គេបញ្ជូនទៅពីពេទ្យស្រុកមកតែកាលខ្ញុំនៅខាងល្វាអែមទេណា។

ក៖ ចា។

ខ៖ ដល់ពេលចឹងទៅខាងគាត់នុះបញ្ជូនមក។

កៈ អត់អីទេបងអោយអូនលេងទៅ។

ខៈ ហើយគេខាងៗនុះ ខាងល្វាអែមនិងគាត់ខាងប្តីខ្ញុំ កាលណាគាត់ឃើញចឹងគាត់ជួយ ជួយទៅអើគាត់អោយយើងទៅមណ្ឌលសុខភាព គេថាអត់កើតគេបញ្ជូនមកពេទ្យរុស្សីយើងនេះ។

កៈ ចា។

ខៈ ខ្ញុំវះសនៅពេទ្យរុស្សីនិង។

កៈ ចា។

ខៈ បានអង្គការខាងនិងគេជួយតាស កាលជួយអង្គការនិងគាត់ជួយយើងហាណាស់។ ហើយអោយយើងមួយថ្ងៃប្រាំពាន់។

កៈ ចា។

ខៈ បានបាយគេបើកអោយ ហើយក្រោយមកខ្ញុំវះសបានមួយខែកន្លះ ប្តីខ្ញុំនិងគាត់វះសទៀត។

កៈ ចា។

ខៈ បានអង្គការនិងគេជួយទៀត។

កៈ ចាគាត់វះសពោះវៀនដុសខ្នែងនុះបង?

ខៈ គេជួយមើលយើងណាស់។

កៈ ចាគាត់វះសពោះវៀនដុសខ្នែងនុះបង?

ខៈ ចាគាត់វះសពោះវៀនដុសៗខ្នែង ធ្វើការវះសគាត់ហើយបានប៉ុនន្មាន ហើយធ្វើការធន់អត់បានទៀត។

កៈ ចា។ ហាហាហា អាអូន។

កៈ ចាហើយចឹងខ្ញុំចង់សួរបងថាសំរាប់អើ តើក្រុមគ្រួសាររបស់បងប្អូនបងនិងណា ដែលគាត់មានក្រុមគ្រួសារហើយនិងអាឡូវពួកគាត់រស់នៅខេត្តផ្សេងៗឬក៏ ពួកគាត់រស់នៅក្នុងភូមិនិងជាមួយគ្នាដែលបង?

ខ៖ នៅក្នុងភូមិនិងមានតែ មើលមានតែបីរបួនគ្រួសារទេ។

ក៖ ចា។

ខ៖ ក្រៅពីនិងគាត់ទៅឯនុះអស់ហើយ ទៅខាងក្រៅ។

ក៖ ចា។

ខ៖ ហើយអើប្អូនស្រីខ្ញុំនិង គឺវាមានបញ្ហារប្ដីវា។

ក៖ ចា។

ខ៖ នៅនេះក្រោយនេះ មុខផ្ទះខ្ញុំនិងខាងក្រោយនេះនិង ជួលដីគេ
ជួលផ្ទះគេនៅនិងទាំងអស់គ្នានិង។

ក៖ ចា។

ខ៖ ប្ដីវានិងមានស្រីនិងទៅបាត់ទៅ គេទៅចោលវាទៅ។ អាឡូវនិងវានៅតែបីនាក់ម៉ែកូន។

ក៖ ចាហើយចឹងខ្ញុំចង់សួរបងទៀតថា
តើបងមានអើសាច់ញ្ញាតិបងប្អូនដែលរស់នៅក្រៅប្រទេសដែលទេបង?

ខ៖ ខ្ញុំមានតែឪពុកចិញ្ចឹមដែលនៅប្រទេសគេ
នៅអង្គរការគេអោយបានចិញ្ចឹមតាំងពីនិងមក ខ្ញុំមានតែមួយនិង ចាក្រៅពីនិងគឺគ្មានទេ។

ក៖ ចា។

ខ៖ អាអូន។

ក៖ ទៅហើយបង។

ខ៖ អត់អីទេអ្នកគ្រូវាអត់ធ្លាក់ទេ។ អោយវាលេងចុះ វាអត់ចេះចុះទេ។

ក៖ ចាបងុ។ ហើយចឹងអើខ្ញុំសូមរំខានបងតិចទៀត
ខ្ញុំចង់សួរបងថាតើស្វាមីនិងភរិយារបស់បង អរស្សាមីរបស់បងនិងមានឈ្មោះអីគេដែល?

ខ៖ ប្ដីខ្ញុំនិងឈ្មោះអើ គៀន សុខឡើន។

ក៖ ឈ្មោះគឿន សុខឡើន។

ខ៖ ចា។

ក៖ ហើយចុះបងបានរៀបអាពាហ៍ពីពាហ៍ជាមួយគាត់និង នៅឆ្នាំណាខែណាដែលបង?

ខ៖ ខ្ញុំអត់បានរៀបទេ អត់បានរៀបការទេខ្ញុំ។
ខ្ញុំស្រលាញ់គ្នានិងខ្ញុំនៅជាមួយគ្នាតែម្តងទៅ។

ក៖ ចាអត់អីទេបង អាចនិយាយអោយអស់ពីអារម្មណ៍របស់បងបានណា
មិនបាច់ខ្មាស់អៀនអីទេ។ហើយអើខ្ញុំចង់សួរបងថាតើគាត់ហើយនិងបងបានទទួលការដឹង
លឺពីឪពុកម្តាយទាំងសងខាងទេបង?

ខ៖ ចាបានដឹងលឺទាំងអស់គ្នា ទាំងសងខាង ម៉ែក្មេកខ្ញុំស្រលាញ់ខ្ញុំណាស់។

ក៖ ចាហើយចុះបងបានទទួលថ្លៃជំនួន បង្គប់អីគេខ្លះដែលទេបង?

ខ៖ អត់ទេខ្ញុំស្រលាញ់គ្នា ខ្ញុំស្មោះស្មាករស់នៅជាមួយគ្នាតែម្តង។

ក៖ ចាគឺយើងអើស្មាកចិត្តដើម្បីចាប់ដៃគូគ្នាជាប្តីប្រពន្ធតែម្តង។

ខ៖ ចា។ ទើបតែមកដល់អាឡូវនិងចូលប្រាំពីរប្រាំបួនឆ្នាំហើយ
ហើយខាងម៉ែក្មេកខ្ញុំក៏គេដឹងលឺ គ្រួសារខាងខ្ញុំក៏គេដឹងលឺ ខាងខ្ញុំក៏គេស្រលាញ់ប្តីខ្ញុំ
ខាងគេឯនុះក៏គេស្រលាញ់ខ្ញុំ។

ក៖ ចាបង។

ខ៖ អាចរស់នៅជាមួយគ្នារហូតបាន។

ក៖ ចាបង។

ខ៖ ចាខ្ញុំចេញចូលៗទេថាទៅ ខ្ញុំតាមពិតខ្ញុំរស់នៅជាមួយប្តីខ្ញុំខាងប្តីខ្ញុំអីនុះ
តែខ្ញុំមកនេះគឺខ្ញុំដូចរបៀបថាខ្ញុំ អរនុះអ្នកគ្រូរសរទឹកហើយ។

ក៖ ចាអត់អីទេបង។

ខ៖ នៃអាឡាកូនខូចណាស់។

ក៖ គេរពឹស ហាហាហា។ ហើយអើចឹងខ្ញុំចង់សួរបងខ្លះៗទៀតថា
បងមានធាប់បានរៀនអើពីមុនមកអត់បង? ពីក្មេងៗមកណាស់?

ខ៖ ខ្ញុំបានរៀននៅជាមួយនិងអើ អ៊ុំចៀវដែលគាត់អោយខ្ញុំរៀននិង
នៅអើងសាលាអើជ័យជំនះអេស្តេកាំងនិង។

ក៖ ចា។

ខ៖ ខ្ញុំបានអើគាត់និងអោយខ្ញុំរៀន រៀនហើយគាត់អោយខ្ញុំទៅនៅខាងមណ្ឌល
ហើយខ្ញុំទៅនៅនិងបានប៉ុនន្មានទេ នៅបានប្រហែលមួយឆ្នាំជាងពីរឆ្នាំនិង
ដល់ថ្ងៃប្រាំថ្ងៃប្រាំមួយយើងនិង នេះបងស្រីខ្ញុំគាត់ខ្លាចមានបញ្ហារ ស្រុកប្រទេសនិងនុះ
ក៏គាត់និងទៅយកខ្ញុំមក ហើយខ្ញុំក៏ខានរៀនរហូតមកដល់ទល់តែតឡូវ។

ក៖ ចា។

ខ៖ ខ្ញុំរៀនបានថ្នាក់ទីពីរទីបីរដែលកាលនិង។

ក៖ ចាចឹងបងចាំថាអើបងរៀននៅសាលាណាដែលបង?

ខ៖ ខ្ញុំកាលនៅអើ នៅក្នុងកន្លែងកុមារកំព្រានៅអើមណ្ឌលគេនិង
នៅផ្សារដីហុយគេហៅសាលា វត្តឃ្មួញ។

ក៖ ចា។

ខ៖ គេហៅសាលាវត្តឃ្មួញ។

ក៖ ចាហើយអើយចង់សួរបងថាសាលានិងនៅអើភូមិណា ស្រុកណាដែលបង?
នៅភ្នំពេញយើងទេឬក៏នៅណាដែលបង?

ខ៖ នៅអើ នេះនៅភ្នំពេញថ្មី។

ក៖ អរភ្នំពេញថ្មី។

ខ៖ ចារ។ នៅអាផ្លូវអើនេះ ហួសវត្តសណ្តួងអណ្តែតយើងនិងទៅទៀតគេហៅ
សាលាវត្តឃ្មុញ ឃុំឃ្មុញយើងនិងហើយក្រៅពីនិងខ្ញុំអត់ចាំទេ។

ក៖ ចាហាហាហា។ អត់អីទេបង។ ចឹងខ្ញុំចង់សួរបងទៀតថា
ពេលដែលបងរៀបអាពាហ៍ពិពាហ៍
អើពេលដែលបងបានចាប់ដៃគូគ្នាដើម្បីរស់នៅជាមួយនិងប្តីបងជាស្វាមីភរិយានិងគ្នានិង

នៅពេលដំបូងនិងតើពួកបង អើខ្ញុំចង់និយាយថាដំបូងនិងថីបានជាស្រលាញ់គ្នា? ហើយជួបគ្នានៅពេលណាដែលបង?

ខ៖ ខ្ញុំអើ ខ្ញុំអត់បានទាក់ទងគ្នាអីទេ ដូចជាជួបគ្នានិយាយទូរស័ព្ទអីក៏អត់មានដែល គ្មានប្រវត្តិស្នេហាអីនិងគ្នាទេតែ ខ្ញុំជួបគ្នា។

ក៖ ជួបមុខគ្នាមាននិស្ស័យ?

ខ៖ ចាមាននិស្ស័យហើយក៏ស្រលាញ់គ្នាជាប្តីប្រពន្ធតែមួយដងទៅ គឺនៅថ្ងៃនិងទៅហើយក៏បានគ្នារហូតមក។

ក៖ ចាចឹងអរគុណបង។ ហើយអើខ្ញុំចង់សួរបងទៀតថាតើបងចេះនិយាយភាសារអីផ្សេងទៀតក្រៅពីភាសារខ្មែរទេបង?

ខ៖ ខ្ញុំចេះអង់គ្លេស និងភាសារថៃ។

ក៖ ចាចុះបងចេះច្រើនទេបង?

ខ៖ ខ្ញុំចេះតែនិយាយទេ តែខ្ញុំអត់ចេះអានហើយនិងអត់ចេះសរសេរទេ។

ក៖ ចាតែវាគឺជាទេពកោល្យមួយដែលបងបានចេះនិយាយភាសារអង់គ្លេស ហើយភាសារថៃណាល្អរមែនទែន។

ខ៖ ចាហាហាហារ។

ក៖ ហើយអើខ្ញុំចង់សួរបងទៀតថា អើតើបងមានមិត្តភិត្តដែលធំឡើងជីតស្និតស្នាលធំធាត់ឡើងជាមួយគ្នាទេបង?

ខ៖ មាន។

ក៖ មានគាត់ឈ្មោះអីដែលបង? បងអាចនិយាយរៀប់រាប់បន្តិចបានទេ?

ខ៖ នៅនិងអីក៏ច្រើននាក់ដែល។

ក៖ ចា។

ខ៖ មានស្រី មានប្រុស។

ក៖ ចា។

ខ៖ សុទ្ធតែពីតូចមកធំឡើងមកជាមួយគ្នាទាំងអស់។

ក៖ ចាចឹងបងអើនៅចាំសាច់រឿងអីខ្លះកាលពីនៅក្មេងៗណា
បងលេងជាមួយនិងពួកគាត់ណា?

ខ៖ អរគឺគេគឺកូនប្រធានភូមិ អាឡូវវាមានប្រពន្ធហើយ។

ក៖ ចា។

ខ៖ វានិងមានឈ្មោះថាអាខា គេហៅវាថាអាច្រវាប់ ហើយវាហៅខ្ញុំថាតែមីការតឿៗ
មីខ្លីនិងទេ។

ក៖ ចាហាហាហា កំប្លែង។

ខ៖ ហើយយើងដើររើសអែតចាយជាមួយគ្នា
ហើយរើសអែតចាយហើយដល់ពេលម៉ោងមកផ្ទះ គឺចាំគ្នា ខ្ញុំប្រាប់ថាចាំគ្នា
ព្រោះអីកាលនិងជិះម្ដូឌុបវាអស់តែពីររយទេ ចុះកាលនិងផ្ទះយើងឆ្ងាយនុះ
នៅនុះហួសពេទ្យមេដេងយើងទៀតនុះ។

ក៖ ចាបង។

ខ៖ ទៅដល់វត្តមហាមន្ត្រីហើយនិង រើសអែតចាយនិងលក់អីនិងហើយ
គេហៅអើកន្លែងនិងថាអីគេទេអើគេហៅចាមេភ្លើង។

ក៖ ចា។

ខ៖ នាំគ្នាទៅលក់អែតចាយហើយនិងនាំគ្នាចាំគ្នាហើយ ទាំងអស់គ្រប់ប្រាំនាក់
បានជិះម្ដូអស់មួយពាន់អីចឹងទៅ។

ក៖ ចា។

ខ៖ ជីម្ដូទាំងប្រាំនាក់ មួយនាក់ពីរៗអីចឹងទៅគ្រប់ប្រាំនាក់បានមួយពាន់
បានម្ដូឌុបគេនិងឌុបមក។

ក៖ អរចា។

ខ៖ ចឹងក៏នាំគ្នាចាំគ្នាទៅ ពេលបានដល់បួននាក់ហើយ
បើមានបួននាក់ខ្វះពីរយទៀតបានមូតូគេឌុបមកហើយអាឡូវនិងអាណាមានលុយច្រើនិង
ចេញសិនទៅ ចាំស្អែកម្នាក់ម្តង។ ហើយទៅខ្ញុំថាអាចាវាប់ឯចេញទៅ
ព្រោះឯប្រុសអញស្រី។

ក៖ ហាហាហាចា។

ខ៖ រួចហើយវាថាអោយអញចេញរហូតចឹង?
រួចខ្ញុំចាអើបើឯរកលុយបានច្រើនជាងពួកអញ។
អញថ្ងៃនេះអញរកបានតែមួយពានប្រាំអីចឹងណាស់។

ក៖ ចា។

ខ៖ ហើយវាថាអញរកបានបីរពាន់ អើបើបីពាន់ឯងចេញមូតូឌុបមួយរយទៅ
ហើយចាំពេលទៅរៀនអញៗទិញនំអោយឯស៊ីវិញ។

ក៖ ចាហាហាហា។

ខ៖ អើមិញនិងខ្ញុំក៏ នេះវារត់មូតូនៅនិងមុខយើង កន្លែងឡឺឡានេះ។

ក៖ ចាអរ។

ខ៖ និងហើយ។

ក៖ ចាចឹងគាត់គឺជាមិត្តភិក្តជិតស្និតរបស់បងដែលស្និតជាងគគមែនទេបង?

ខ៖ ចាអានិងនៅរាល់ថ្ងៃនិងក៏វានៅលេងដែល វាឃើញខ្ញុំលៀបសក់ពណ៏ក្រហមអីនិងវាថា
អញមិស្សលមិញមេយក្រហមដល់ហើយ
ចេះដូចភ្លើងឆេះកាលចឹងមិនដឹងជាឆេះនៅណាទេស្រុកខ្មែរនេះ។ចឹងទៅខ្ញុំមើលទៅមេយ
ហើយខ្ញុំឆ្ងល់ ដល់ពេលហើយទៅគេថាគេ ថាអោយខ្ញុំនិងណា។

ក៖ ចាហាហាហា។

ខ៖ ដល់ពេលហើយទៅខ្ញុំក៏ចេវាថា អាត្រូក្រាប់ខ្ញុំចេវាចឹង ព្រោះវាធាប់លេង
តែអត់ដែលចេះចេម៉ែគ្នាអីទេ លេងតែត្រឹមគ្នាៗឯងនិង។

ក៖ ចាបង។

ខ៖ ព្រោះវាធំៗអស់ហើយ ធំមកជាមួយគ្នានិយាយរូមគឺតាំងតែពីតូចមក តាំងតែពីមិនទាន់ចេះស្លៀកខោរ។

ក៖ ចាហាហាហា សប្បាយ។

ខ៖ តាំងពីនៅបឹងកាប្លោកមកមេស តែរត់ទៅអត់មានផ្ទះទេមានតែស្មៅ អង្កើតែស្មៅទេ នាំគ្នារត់លេងនៅក្នុងស្មៅនិង គឺថាអង្កើតែស្មៅអត់ឃើញមនុស្សទេ ចាស់ៗនិងមិនស្រួលថាសត្វអីផងមិនដឹង។ព្រោះកាលនិងអត់មានផ្ទះទេមានតែព្រៃ នេះនៅកន្លែងនិងកាលនិងមានដើមបបូស ឆ្អឹងគារអីនិងនេះនៅនិងណាស់។

ក៖ ចាចុះផ្ទះនិងផ្ទះបងខ្លួនឯងឬក៏នេះ?

ខ៖ អានិងផ្ទះខ្ញុំជួលគេ។ ខ្ញុំគ្មានផ្ទះនៅផង។

ក៖ ចាអត់អីទេបងខំប្រឹងតិចទៀត។ ហាហាហា។

ខ៖ ហាហាហា។

ក៖ ហើយអរគុណបងសំរាប់ថ្ងៃនិង ហើយខ្ញុំចង់សួរបងទៀតថាបងធ្លាប់ធ្វើការនៅវាលស្រែដែលទេ?ឬក៏ប្រកបមានប្រកបអាអីរកម្មអីផ្សេងៗទេបង?

ខ៖ នេះខ្ញុំមានដែល ព្រោះម្តាយខ្ញុំកាលនិងទៅនៅមណ្ឌលកុមារកំព្រានិងអើខាងអង្គរការនិងគាត់អោយយើង ហើយពួកជនជាតិគេដែលនិងណា គេចុះមកជួយធ្វើស្រែ គេចង់អោយយើងនិងខ្មែរនិងចេះមានការយល់ ការដាំស្រូវ យកអង្ករអីនិងណា យកពីស្រណាំមកស្ទូង យកពីស្ទូងមកបានចេញជាស្រូវអីចឹងទៅណា។

ក៖ ចាមិនមែនស្រណាមទេ?

ខ៖ ចាដល់ពេលនេះទៅខ្ញុំគេអោយជ្រូត ដល់តែជ្រូតៗទៅកណ្តៀវនិងវាមុតដៃនេះ នេះខ្ញុំមានស្នាំមដៃនេះ។

ក៖ ចាអើម។

ខ៖ កាលពិតទៅក្មេងបឹងត្របែកយើងនិងអីអង្គរការនៅជ័យជំនះអេស្តេការនិងគេចិញ្ចឹមទាំងអស់ យើងបានចូលរៀននៅក្នុង។

ក៖ ចានៅក្នុងអង្គការនិង?

ខ៖ ចាអង្គការនិងគឺអើអ៊ុំចៀវនិង ខ្ញុំចាំឈ្មោះគាត់បាន ហើយនិងម៉ាក់ តែអាឡូវនិង។

ក៖ នុះអាអូនស្រែកទឹកទេអីបង? រកទឹកដាក់មាត់ហើយ។

ខ៖ ហើយអង្គរការនិងម៉ាក់អើខ្ញុំហៅគាត់ថាតែម៉ាក់ទេ ព្រោះក្មេងនៅក្នុងនិងហៅគាតើថាម៉ាក់ទាំងអស់តែឥឡូវគាត់បានធ្វើនៅអង្គការអីនេះ អង្គការអើសង្គ្រោះមាតានិងទារក ហើយគាត់ចិញ្ចឹមទឹកដោះគោអាអូនរាល់ថ្ងៃនេះ។

ក៖ ចាអើម ចឹងកូនរបស់បងអាអូនមានអ្នកគាត់ផ្តល់ទឹកដោះគោអោយខ្លះហើយមែនទេបង?

ខ៖ ចាអង្គរការគេជួយយើងទៅសុំគេមក ព្រោះយើងវាគ្មានសមត្ថភាព។

ក៖ ចាត្រូវហើយបង។

ខ៖ នេះគាត់បើកទឹកដោះគោនេះអោយ មួយអាទិត្យគេបើកអោយម្តង។ ចាប់តាំងពីអាអូនបានប៉ុនន្មានខែទេ ដូចជាបានបីរខែពីរខែនិង យើងវាអត់សមត្ថភាពនិងទិញនុះ យើងទៅសុំគាត់ទៅ គាត់អោយហើយគាត់ឃើញខ្ញុំនិងទៅ គាត់ថាអើម៉ាក់ធ្លាប់ចិញ្ចឹមយើងនិង។

ក៖ ចាចឹងខ្ញុំចង់សួរបងទៀតថា បងបន្ទាប់ពីការធ្វើស្រែនិងបងមានធ្លាប់លក់ដូរឬក៏ប្រកបអាជីវកម្មអីផ្សេងៗដែលបងធ្លាប់ធ្វើឬក៏កុំពង់តែធ្វើនៅសព្វថ្ងៃនិងទេ?

ខ៖ ខ្ញុំអាឡូវអត់ធ្វើអីផងនិង ខ្ញុំនៅតែផ្ទះនិងនៅមើលតែកូននិងបើខ្លួនខ្ញុំនិងឈឺតែរហូតនិង តែប្តីខ្ញុំទេគាត់រើសអែតចាយហើយនិងធ្វើសំណង់។

ក៖ ចា។

ខ៖
ចង់ទៅធ្វើអីនិងគេដែលតែប្តីខ្ញុំគាត់ថាធ្វើមិនត្រូវជ្រុងទេបើមើលតែកូនមួយប៉ុនិងនៅមើលមិនជាប់ផង។

ក៖ ចាចឹងបងនៅផ្ទះមើលអាអូន។ ចឹងខ្ញុំចង់សួរបងទៀតថាអើ
តាំងពីក្មេងរហូតមកដល់ពេលនេះណាតើជីវិតរបស់បងនិងមានការផ្លាស់ផ្តូរអ្វីខ្លះដែលអត់?

ខ៖ អូយផ្លាស់ប្តូរច្រើន កាលខ្ញុំនៅពីតូចពីបាកច្រើន។

ក៖ ចាបង។ ចាដល់ពេលធំឡើង?

ខ៖ ធំមានប្តីក៏នៅតែពីបាក តែវាពីបាកគ្រាន់ជាងកាលយើងនៅពីក្មេង។
ពីក្មេងយើងត្រដាប់ត្រដួសរស់ ដល់ពេលធំយើងត្រដាប់ត្រដួសដែលតែពេលកូនឈឺ
ខ្លួនយើងអីនិងឈឺ យើងជំពាក់គេចឹងណាយើងខ្ចីគេ ហើយយើងរកមិនបាន
រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹកចឹង។ ដល់ស្មើនិងមិនទាន់បានបាយហូបផង
ហើយក្នុងខ្លួនគ្មានមួយរយទេ ដល់យើងទៅធ្វើការ
ហើយថាប្រមូលអែតចាយយកទៅលក់មិនទាន់បានយកទៅលក់ផងហើយ
គេងនុះពឹងអោយទៅជួយធ្វើផ្ទះអោយគេនិង គេនុះប្រយាប់នៅដែលណា
ហើយខ្ញុំធ្វើអីកើតអាឡូវកុំពង់តែអាជើងនិងវាកើតអាស្អីគេជំបៅនេះវាចាប់ជើងខ្ញុំនិងមួយយប់ហើយ។ មិនទឹងមានថ្នាំលេបផង។

ក៖ ចាបងអានីងបងកើតអីគេដែលបង?

ខ៖ ខ្ញុំអាលាកធុកមូស ហើយទៅវាទៅជាដំរ ហើមកាលៀនហើយដើរអត់ចង់រួច
ឈឺអានិងយប់មិញខ្ញុំចាប់ណាស់ខ្ញុំដេកអត់លក់ទេ។

ក៖ ចាចាំមើលខ្ញុំរកថ្នាំអោយបង តែចាំល្ងាច។

ខ៖ ហើយវាដំរៗដល់ការលៀនយើងនេះ ដើរអត់បានណា អង្គុយបត់អីក៏មិនបានយូរដែល
អង្គុយក៏មិនបាន ឈរក៏មិនបាន។ ហើយប្តីខ្ញុំគាត់ គាត់អស់កំលាំងរើងអែតចាយផង
គាត់រើសអែតចាយតាមលូរយើងនិងហើយអើក៏ឆ្លាតទៅធ្វើផ្ទះអោយគេនុះទៅ។
ហើយបើយើងមិនចែកពេលវេលាទេយើងអត់មានលុយហូបបាយទេ។

ក៖ ចាបង។

ខ៖ មើលអាឡូវម៉ោងជិតមួយអាឡូវហើយខ្ញុំមិនទាន់មានហូមបាយផង ហើយតែមួយរយក្នុងខ្លួនក៏គ្មានដែលជីវិតខ្ញុំពីនាក់ប្ដីប្រពន្ធនិង។

ក៖
អើចឹងខ្ញុំសូមសួរបងទៀតថាតើមានម្ហូបណាដែលបងចូលចិត្តជាងគេណាបងតាំងពីក្មេងរហូតមកដល់ពេលនិងណា?

ខ៖ ខ្ញុំម្ហូបអីក៏អត់នេះដែលសំខាន់អើ ខ្ញុំខ្លាចតែឆ្លាក់ឆ្អឹងត្រីទេ។

ក៖ ចាបងឆ្លាក់ឆ្អឹងត្រី។

ខ៖ ចាម្ហូបអីក៏ខ្ញុំនេះដែល ក៏ហូមបានដែលបើប្ដីខ្ញុំវិញគាត់ចូលចិត្តជាងគេគឺទឹកត្រីដែលម៉ែគាត់រំងាស់។

ក៖ ទឹកត្រីរំងាស់អរ ទឹកត្រីគាត់ធ្វើខ្លួនឯងនុះ?

ខ៖ ចានិងហើយ ទឹកត្រីគាត់ធ្វើខ្លួនឯងម៉ែគាត់ពិនរំងាស់ទឹកត្រីធ្វើប្រហុកណាស់។ នែកពេលទៅផ្ទះល្វាអែមម្ដងៗគឺដឹងតែច្រក់យកមកហើយ គាត់អោយមកតែអាឡូវគាត់អស់ហើយប្រហុកនោះ។

ក៖ ចាបង។ ហើយចុះបងចេះធ្វើវាអត់? ចេះធ្វើពីគាត់ទេ?

ខ៖ ចេះគាត់បង្រៀន។

ក៖ ចេះដែលអរហុះ ហាហាហា។

ខ៖ ម៉ែក្មេកខ្ញុំគាត់បង្រៀនអោយចេះធ្វើ។

ក៖ ចាហើយអើចឹងខ្ញុំចង់សួរបងទៀតថាអើតាំងពីក្មេងមក តើបងធ្លាប់លេងល្បែងអីគេខ្លះដែលបងចូលចិត្តជាងគេ ដូចជាលេងល្បែងចោលឈូកបោះអង្គុញអីណា?

ខ៖ អរខ្ញុំចូលចិត្តលេងអីអាគេលេងបិទភ្នែកនុះ?

ក៖ អើប្រវត់?

ខ៖ មិនមែនទេអាលេងដូច?

កៈ អើឆ្មាចាប់កណ្តុល?

ខៈ អត់ទេខ្ញុំអត់ ខ្ញុំធ្លាប់នៅពីក្មេងខ្ញុំធ្លាប់លេងអីគេ គេហៅថាកូនប្រសារពង្រាត់ម៉ែឪ ពង្រាត់កូនប្រសារម៉ែក្មេកគេនុះ អោយចាប់ដៃគ្នាគូៗនុះ។

កៈ ចាអរ។

ខៈ ហើយហត់ណាស់ហើយ បើលេងលាក់កន្សែងវីញឈឺខ្លួនណាស់គេវីញមែនទែន ខ្ញុំអត់លេងទេ ហើយបោះអង្គុញ
ខ្ញុំចូលចិត្តលាងបោះអង្គុញហើយនិងគេហៅខ្សឹបការនោះ។

កៈ អានិងគេហៅថាលេងខ្សឹបការ។

ខៈ និងហើយលេងខ្សឹបការ គេលេងបិទភ្នែកនិងហើយ។
លេងខ្សឹបការខ្ញុំចូលចិត្តលេងអានិង ព្រោះវាស្រួលអត់ឈឺទេ។
ខ្ញុំចូលចិត្តលេងតែបោះអង្គុយ ហើយនិងខ្សឹបការ
ក្រៅពីនិងខ្ញុំអត់ចូលចិត្តលេងទេព្រោះគេលេងឈឺៗខ្ញុំអត់ចូលចិត្តលេងទេ។

កៈ ចាហាហាហារ បងខ្លាចឈឺ?

ខៈ ចាហាហាហារខ្ញុំខ្លាចឈឺណាស់។ ត្រូវជើងកូន (គាត់និយាយទៅកាន់កូនរបស់គាត់)។

កៈ ចាហើយចឹងខ្ញុំចង់សួរបងទៀតថាបងធ្លាប់អើច្រៀងចំរៀងអីដែលបងចូលចិត្តអត់បង?

ខៈ ខ្ញុំធ្លាប់ច្រៀងចំរៀងបទពីដើមៗ ច្រៀងបទពីដើមនិងគឺខ្ញុំចូលចិត្តច្រៀងលេងនិងណា។

កៈ ចាចុះបទនរណាគេដែលបងចូលចិត្តណាស់ ដូចជារស់សិរីសុធាអី?

ខៈ ខ្ញុំចូលចិត្តរស់សិរីសុធា ហើយនិងប៉ែនរ៉ន។

កៈ អរចា។

ខៈ ខ្ញុំចូលចិត្តព្រោះបទពួកគាត់ពីរោះៗណាស់ ហើយតមកឥឡូវនិងគឺខ្ញុំចូលចិត្តបទ ហឹមស៊ីវ័ន។

កៈ ចា។

ខៈ ក្រៅពីនិងខ្ញុំអត់មានជំនូលចិត្តទេ ព្រោះពួកគាត់ច្រៀងវាមានន័យ។

ក៖ ចាបងពួកគាត់ច្រៀងពីរោះៗណាស់ៗចា។

ខ៖ នែត្រូវជើងមក(គាត់និយាយអោយកូនគាត់)។

ក៖ អរឈប់លេងៗមក ហាហាហា។

ខ៖ មកយកមកអោយម៉ាក់ វាចូលចិត្តលេងតែរបស់ឪពុកវានិង។
វាចូលចិត្តលេងធ្វើគ្រឿងសំណង់ ដូចជាអាញួរ
ពូថៅអីនិងសប្បាយចិត្តណាស់អោយតែបាន។

ក៖ ចាគាត់ចូលចិត្តលេង ចង់ធ្វើខាងវីស្វ័ករ។

ខ៖ និងហើយអោយតែថ្ងៃអាទិត្យឡើងប៉ាវាមកពីធ្វើការវិញនិង វារត់ទៅហើយ
វារត់ទៅទទួលតែពូថៅអាញ័រវានិង។

ក៖ ចាចឹងបងខ្ញុំចង់សួរទៀតថាអើ តើនៅក្នុងសមាជិតក្រុមគ្រួសារបងណា
តើមាននរណាម្នាក់ដែលគាត់ចេះលេងឧបរកណ៏ភ្លេង ឬក៏តន្ត្រីអីដែលទេបង?
ដូចភ្លេងខ្មែរភ្លេងយើងសម័យអីនិងចេះទេ?

ខ៖ អត់ផង បងប្អូនបងអត់មានពីណាចេះលេងភ្លេងទេ។

ក៖ ចា
ចុះតើផ្ទះរបស់បងវិញតើមានលក្ខណះបែបណាដែលចឹងណាស់តាំងពីបងនៅក្មេងរហូតដ
ល់ឥឡូវនិងណា?

ខ៖ ខ្ញុំគ្មានផ្ទះនៅទេ
ផ្ទះម៉ាក់ក្មេកខ្ញុំនៅខាងល្វាអែមនិងគឺពួកខ្ញុំគ្រាន់តែសុំផ្ទះគាត់ជ្រូកកោននិងនៅជាមួយគាត់
ទៅ។ ហើយមកនៅភ្នំពេញនេះគឺផ្ទះជួលគេទៀត ព្រោះខ្ញុំមិនទាន់មានផ្ទះនៅខ្លួនឯងទេ។
កុំចុះក្រោមកូន។

ក៖ ចាចឹងខ្ញុំចង់សួបងទៀតថាប្តីរបស់បងគាត់ចេះសាងសង់ផ្ទះនិង
តើបងចេះដូចគាត់អត់បង?

ខ៖ ខ្ញុំអត់ចេះផង ហាហាហារ។ ប្តីខ្ញុំគាត់ចេះជាងធ្វើជាងសំណង់ បើខ្ញុំវិញអត់ចេះអីទេ។

ក៖ ចាចុះបងប្រុសគាត់ចេះនិងគាត់អើរៀនមកពីណាដែលឬក៏មេចដែលបង
គាត់ចេះខ្លួនឯងមែន?

ខ៖ គឺគាត់ទៅធ្វើការជាមួយគេហើយទៅគាត់លួចមើលគេនិង
គាត់លួចមើលដំរិះគេចឹងទៅមើលទៅគាត់ឃើញថាគាត់អាចចាប់បាន។

ក៖ ចាគាត់ឆ្លាត។

ខ៖ ចាគាត់អាចចាប់បាន ចា។

ក៖ អើចឹងខ្ញុំចង់សួរបងទៀតថា
ការសាងសង់ផ្ទះនិងណាតើបងប្រុសគាត់មានសំភារះអីគេខ្លះដែល
គាត់ត្រូវយកទៅដើម្បីសាងសង់ណា?

ខ៖ ខ្ញុំមិនសូវដឹងដែល តែបើគាត់ធ្វើផ្ទះឈើគឺគាត់មានតែពូថៅ អាញ្ញ័អីនិង
ហើយនិងអាណា។ ហើយបើទៅធ្វើផ្ទះគេរបៀបថាធ្វើផ្ទះថ្មរផ្ទះអីនិង
គឺត្រូវប្រាប់គេម្ចាស់ផ្ទះនិងថាយើងអត់មានសំភារះគ្រប់គ្រាន់។

គ៖ សុខាហាមានអានេះទេ។

ខ៖ អត់ដឹងទេទល់តែចាំសួរប៉ាវាសិនចាំមើលខ្ញុំសួគាត់អោយ
ឥឡូវគាត់សំរានហើយចាំតិចទៅណាអូនណា។

គ៖ ទៅវីញហើយ។

ខ៖ អើ។ ដល់ពេលហើយយើងប្រាប់ម្ចាស់គេទៅថាយើងអត់មានអី យើងមានរបៀបដូចថា
ប៉ែល។

ក៖ ចាចឹងអរគុណបង។
បងតើអើបងធ្លាប់មានជំនាញអ្វីខ្លះដែលបងបានរៀនបន្តរពីក្រុមគ្រួសាររបស់បងដូចជាការ
កូស្ករ ធ្វើត្នោត វិញវល្លអី ឬក៏រៀនជំនាញពីម្ដាយក្មេករបស់បងនិងណា គឺបង្រៀនធ្វើប្រហុក
បង្រៀនធ្វើទឹកត្រីអីនិង។

ខ៖ ចាគឺអត់មានអីផង គ្រាន់តែម្ដាយក្មេកខ្ញុំគាត់បង្រៀនខ្ញុំអោយចេះរំងាស់ទឹកត្រី
ហើយនិងអើធ្វើក្រចកដៃ។

ក៖ ចាចុះបងចេះធ្វើក្រចកដៃនិងមកពីណាដែលបង?

ខ៖ ខ្ញុំរៀន។

ក៖ រៀន បងរៀននៅកន្លែងណាដែល កន្លែគេផ្ទល់ឬក៏មេចដែលបង?

ខ៖ អើខ្ញុំរៀននៅថៃ។

ក៖ ចាចឹងបងទៅរៀននៅថៃរយះពេលប៉ុន្មានឆ្នាំដែលបង?

ខ៖ ខ្ញុំទៅរៀនប្រាំមួយខែ។

ក៖ ចឹងបងចេះបងអាចប្រកមមុខរបបអាជីវកម្មមួយនិងបានមែនទេបង។

ខ៖ អើអារៀនអ៊ត់សក់និងខ្ញុំថាម្នាក់ឯងនិងខ្ញុំថាទៅអត់រួចទេ ទល់តែមានគ្នា
ព្រោះអីកាលណាបើមាភ្ញៀវមកយើងម្នាក់ឯងធ្វើតែក្រចក
ហើយចុះបើមានគេមួយទៀតមកធ្វើសក់ យើងម្នាក់ឯងនិងគឺធ្វើអត់ទាន់ទេ
ហើយណាមួយឥឡូវនិងខ្ញុំធ្វើអីក៏អត់កើតដែលខ្ញុំវាមានជំងឺជាប់ខ្លួនចឹងរហូត។

ក៖ ចា។

ខ៖ តែបើធ្វើតែក្រចកនិងខ្ញុំធ្វើបាន ខ្ញុំធ្វើកើតព្រោះអីយើងអាចប្រាប់គេថាអាចចាំបានអត់
អីចឹងទៅគេចាំបានក៏គេចាំ បើគេចាំមិនបានទេក៏អត់ទៅចឹងខ្ញុំអាចធ្វើបាន
អារឿងធ្វើក្រចកដៃក្រចកជើងនិង ខ្ញុំចេះធ្វើ។

ក៖ ចាអរគុណបង។ ចឹងខ្ញុំចង់សួរបងទៀតថា
តើបងអាចប្រាប់ខ្ញុំអំពីពេលដែលបងលំបាកបំផុតនៅក្នុងជីវិតរបស់បងណានៅពេលណា
ដែលបង? ហើយបងឆ្លងគាត់វាដោយរបៀបណាដែល? វាមេចអីមេចចឹងណា?
គឺពេលដែលបងគិតថាពិបាកខ្លាំងណា?

ខ៖ គឺពេលដែលខ្ញុំរះស់ គឺរះស់កូនពីនាក់ប្តីប្រពន្ធគឺខ្ញុំអត់មានលុយ ហើយខ្ញុំពិបាកចិត្តខ្លាំង
គឺខ្វល់និងបារម្មណ៍ ព្រោះថាយើងជំពាក់គេ
ហើយគាលនិងខ្ញុំខ្ចីលុយអង្ការគេដើម្បីទិញសំភារះអោយប្តីធ្វើសំណង់នុះ
ហើយដល់ពេលខ្ញុំធ្លាក់ខ្លួនចឹងដូចថាប្តីខ្ញុំនិង ម៉ៅធ្វើសំណង់អោយគេនេះខាត
ខាតហើយប្រពន្ធក៏រះស់ទៀត ហើយណាមួយនៅក្នុងជីវិតខ្ញុំមិនដែលមានកូនផង

ទើបតែមានកូនទីមួយស្រាប់តែវាកើយទៅជាបែបនិង
រឿងនិងហើយដែលខ្ញុំពីបាកហើយខ្វល់នុះ វាលើទ្រព្យអ្វីៗដែលខ្ញុំមានទៅទៀត។

កៈ ចាអរគុណច្រើនបង។
ចឹងអើខ្ញុំចង់សួរបងថាតើបងឆ្លងកាត់ឧបសគ្គនិងដោយរបៀបណាដែលរហូតមកដល់ពេលនិងណា? ដូចជាបងធ្វើចិត្តមេចអីមេច?

ខៈ រាល់ថ្ងៃនិងខ្ញុំធ្វើចិត្តអត់ទាន់បានទេតែជួនកាលខ្ញុំនៅនឹកឃើញកូនខ្ញុំ
ហើយកាលនិងខ្ញុំបានពេលដែលខ្ញុំរះសើហើយនិងខ្ញុំដេក
ពេលចេញពីពេទ្យមកខ្ញុំដេកយល់សិប្តឃើញកូនខ្ញុំ ខ្ញុំនៅចាំមិនភ្លេចទេ
ខ្ញុំនៅចាំកូននិងគឺមីនភ្លេចទេ ហើយពេលណាខ្ញុំនៅដេកនឹកឃើញគឺខ្ញុំយំ។

កៈ ចាអរគុណបង។ ចឹងខ្ញុំចង់សួរបងអំពីបទពីសោធន៍ល្អៗនៅក្នុងជីវិតបងវិញ
ចឹងតើបងធ្លាប់មានបទពីសោធន៍អីខ្លះដែលល្អៗនៅក្នុងជីវិតរបស់បងដែលធ្វើអោយជីវិតរបស់បងរីករាយនៅក្នុងជីវិតណា?

ខៈ ខ្ញុំគឺពេលដែលខ្ញុំបានជួបប្តីខ្ញុំនេះ
ដែលធ្វើអោយខ្ញុំមានបទពីសោធន៍ថាអ្វីដែលហៅថាគ្រួសារភាពកក់ក្តៅ។

កៈ ចាមានសេចក្តីស្រលាញ់អីចឹងទៅ។

ខៈ ចាកាលពីមុនខ្ញុំអត់ដឹងអី របៀបដូចថាខ្ញុំនៅក្មេងក៏ថាបានដែល
តែថាខ្ញុំអត់បានដែលស្គាល់អ្វីដែលហៅថាគ្រួសារ
ខ្ញុំអត់ដែលដឹងថាអ្វីជាអ្វីទេ។តែខ្ញុំបានប្តីខ្ញុំក្រោយនិងទើបខ្ញុំបានស្គាល់អ្វីទៅដែលហៅថាគ្រួសារ ហើយក៏ដឹងថាខ្លួនឯងនិងជាប្រពន្ធគេ
កាលមុនខ្ញុំឆល់ថាអ្វីទៅជាមេផ្ទះជាប្រពន្ធគេជាម្តាយគេថាយើងនេះត្រូវធ្វើយ៉ាងមេច។
ហើយគឺខាងម្តាយក្មេកខ្ញុំនិងបងប្អូនថ្លៃខ្ញុំនិងប្តីខ្ញុំនិងគឺគេប្រដៅនិងបង្រៀនអោយស្គាល់អីចឹងទៅណាស់ រួចទៅបានខ្ញុំចេះ
ហើយក៏ខ្ញុំមានភាពមួយដែលថាសប្បាយចិត្តដែលខ្ញុំបានស្គាល់ប្តីខ្ញុំនិងណា
ហើយគាត់ផ្តល់ភាពកក់ក្តៅអោយខ្ញុំ។

កៈ ចាចឹងប្តីរបស់បងគឺជាក្តីសង្ឃឹមរបស់បងនៅក្នុងជីវិតរបស់បង។ ហើយអើខ្ញុំចង់សួរបងទៀតថានៅពេលដែលបងនៅពីក្មេងតើបងធ្លាប់មានសង្ឃឹមចង់ធ្វើអ្វីដែលនៅពេលដែលបងធំឡើងណា? ធ្លាប់មានទេបង? ក្តីស្រមៃរបស់បងណា?

ខៈ ក្តីស្រមៃខ្ញុំកាលពីក្មេងខ្ញុំប្រាប់ថាខ្ញុំចង់ក្លាយជាអ្នកចំរៀង ព្រោះអីខ្ញុំចូលចិត្តច្រៀង។

កៈ ចាបង។

ខៈ និងហើយ ហើយដល់ពេលមកដល់ពេលដែលខ្ញុំបាត់បង់ម្តាយហើយដល់ចឹងទៅ ខ្ញុំក៏មករស់នៅភ្នំពេញជាមួយបងស្រីខ្ញុំនិង ដល់ពេលចឹងទៅខ្ញុំលែងគិតហើយព្រោះយើងរស់នៅជាមួយគេនិងនៅមណ្ឌលកុមារកំព្រា និង ខ្ញុំបានតាំងចិត្តខ្ញុំថាខ្ញុំនិងខំរៀនហើយ ខ្ញុំថានៅមណ្ឌលកុមារកំព្រានិងគេថានិងផ្គត់ផ្គង់យើងអីចឹងណា ហើយខ្ញុំថាខ្ញុំនិងខំរៀនហើយខ្ញុំចង់ក្លាយជាតារាចំរៀងនិងតាំងពីខ្ញុំនៅតូចៗ។ ហើយដល់ពេលបានដល់ថ្ងៃប្រាំ ថ្ងៃប្រាំមួយនិងទៅខ្ញុំថាខ្ញុំគ្មានក្តីសង្ឃឹមអីទៀតទេ ប៉ុន្តែគ្រាន់តែថាខ្ញុំចង់មានគ្រួសារមួយដល់កក់ក្តៅ ហើយឥឡូវតាំងតែពីពេលនិងមករហូតគឺខ្ញុំបានជួបគ្រួសារមួយដែលកក់ក្តៅ ទោះបីរជាខ្ញុំអត់ក៏ខ្ញុំមានភាពកក់ក្តៅនៅក្នុងជីវិតរបស់ខ្ញុំគឺធ្វើអោយខ្ញុំសប្បាយចិត្ត។

កៈ ចាអរគុណបង។

ខៈ ដូចជាពេលនេះចឹង ពេលនេះខ្ញុំអត់មានមួយរយទេតែខ្ញុំសប្បាយ អ្នកដែលគេមើលមកពីខាងក្រៅគេមើលមកគេថាខ្ញុំនិងសប្បាយចិត្តណាស់ ខ្ញុំនិងមើលទៅគឺមានក្តីសុខណាស់ គឺខ្ញុំសប្បាយចិត្តមែន ខ្ញុំអត់តែខ្ញុំមានភាពកក់ក្តៅ។ អត់ស៊ីមានស៊ីខ្ញុំរស់នៅជាមួយគ្នាខ្ញុំអត់ឈ្លោះគ្នាគឺខ្ញុំសប្បាយចិត្តណាស់ ព្រោះប្តីខ្ញុំអត់ចេះឈ្លើយ អត់ចេះចឡើសបើស់អីទេ ហើយគាត់និយាយជាមួយខ្ញុំសុទ្ធតែខ្ញុំរហូត គាត់អត់ចេះមាត់អត់ចេះករទេ។

កៈ ចាគាត់គឺជាមនុស្សល្អ។

ខៈ ចានៅនិងអ្នកណាក៏សរសើរគាត់ដែល ព្រោះគាត់អត់ចេះមាត់អត់ចេះខ្វែលខ្វល់ពីអ្នកណាអត់ស៊ីមានស៊ីទេគឺគាត់អត់ខ្វល់ទេ គាត់គិតតែរឿងថាគាត់មានបាយហូបអត់ហើយប្រពន្ធគាត់និងទៅណាធ្វើអី

មកដល់ផ្ទះគាត់ឃើញប្រពន្ធកូននៅក្នុងផ្ទះគឺគាត់សប្បាយចិត្តហើយ
គាត់មើលនៅក្នុងផ្ទះមានបាយមានម្ហូបអ្វីនអីចឹងគឺគាត់សប្បាយចិត្តហើយ
ហើយគាត់អត់និយាយទេគឺគាត់អត់បចចេះនិយាយតែម្ដង
ចេះតែញញឹមនរណាគេហៅបងពូអី គាត់ឆ្លើយតែបាទៗ
បានតែចឹងអ្នកនៅនិងគេដឹងថាគាត់អត់ចេះនិយាយ។

ក៖ ចាអរគុណបង។ ចឹងអើខ្ញុំចង់សួរបងទៀតថាបើសិន
ជាអាចតើបងនិងផ្ដាំប្រាប់អ្វីខ្លះទៅកាន់កូនចៅជំនាន់ក្រោយរបស់បង
នៅពេលដែលគាត់ធំឡើង បងចង់អោយគាត់អើធ្វើអីខ្លះ អោយគាត់រៀនឬក៏គាត់ខំអី?

ខ៖ ខ្ញុំចង់អោយពួកគាត់ទាំងអស់គ្នានិងរៀន
ហើយទោះបីរៀនក៏ដោយមិនរៀនក៏ដោយមនុស្សយើងមានសតិសាមបិជនះនីក្នុងខ្លួនគ្រប់
ៗគ្នា។ ខ្ញុំគ្រូតែចង់អោយពួកគាត់ទាំងអស់គ្នានិងបានស្គាល់ពីចាស់ទុំ អោយចេះគោរព
ទោះជាពួកខ្ញុំចាស់ក៏ដោយឆ្កួតជាដើរស្រោតក៏ដោយ
ខ្ញុំចង់អោយពួកគាត់ជាក្មួយៗនិងកូនៗនិង អោយចេះគោរព
ទោះឆ្កួតក៏តាមស្លៀកខោអាវអោយដែល។ ព្រោះខ្ញុំចង់អោយពួកគាត់ចេះស្គាល់គុណ
មកទីនេះខ្ញុំឃើញក្មួយៗខ្ញុំនិងឆ្លើយៗណាស់ មើលងាយម្ដាយមីងខ្ញុំអត់ចង់បានចឹងទេ
ខ្ញុំចង់អោយពួកគាត់និងស្គាល់គុណ ស្គាល់ទោស ស្គាល់ខ្ពស់ទាប
មិនថាចំពោះតែម្ដាយមីងទេ អ្នកដ៏ទៃក៏យើងត្រូវតែគោរពដែល។
ខ្ញុំមើលទៅវាល់ថ្ងៃនិងគ្មានដឹងអាណាមីងអាណាបងអាណាប្អូនអីទេ
ខ្ញុំមើលទៅវាទុកយើងលើសអ្នកដ៏ទៃទៀតនិងណា
ចង់អោយពួកគាត់និងចេះស្គាល់គុណស្គាល់ទោសតែប៉ុននិងខ្ញុំអត់ចង់បានអ្វីទៀតទេ។

ក៖ ចាចឹងខ្ញុំសូមអរគុណបងសំរាប់កិច្ចសំភាស៏មួយនិង
ចឹងជាចុងក្រោយខ្ញុំសូមអរគុណបងដែលបានជួបខ្ញុំអោយនិយាយពិភាក្សាជាមួយនិងបង។
ហើយចឹងបងមានអីទៀតទេបងចង់ផ្ដែផ្ដាំប្រាប់កូនចៅជំនាន់ក្រោយណា?
ដូចជាអត់ទេអស់ហើយនុះបង?

ខ៖ និងហើយអស់ហើយ។

ក៖ ហាហាហារចាចឹងអរគុណច្រើនបង។